# សេចក្តីជូនដំណឹងអំពីព័ត៌មានបន្ថែម (NOAI) ស្តីពីសិទ្ធិ និងអត្ថប្រយោជន៍របស់អ្នកអំពីកម្មវិធី California Children’s Services (CCS)

## 1. តើកម្មវិធីនឹងផ្លាស់ប្តូរដូចម្តេចខ្លះ?

ច្បាប់ថ្មីនៅរដ្ឋ California នឹងផ្លាស់ប្តូររបៀបដែលកូនរបស់អ្នកទទួលសេវាកម្មនានារបស់កម្មវិធី California Children’s Services (CCS)។ ចាប់ពីថ្ងៃ **1 ខែមករា ឆ្នាំ 2025** គម្រោង Medi-Cal នឹងពង្រីកកម្មវិធី WCM ទៅកាន់ខោនធីនៃរដ្ឋ California ចំនួន 12 ខោនធីបន្ថែមទៀត។ នៅក្នុងខោនធីទាំង 12 នោះ គម្រោងសុខភាព Medi-Cal នឹងត្រួតពិនិត្យការសម្របសម្រួលការថែទាំ ការគ្រប់គ្រងករណី និង California Children’s Services (CCS) ផ្សេងទៀតសម្រាប់កុមារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ CCS។ ឥឡូវនេះ កូនរបស់អ្នកនឹងទទួលបាន CCS តាមរយៈគម្រោងសុខភាពវេជ្ជសាស្ត្ររបស់ពួកគេនៅក្នុងខោនធីរបស់ពួកគេ។ គេហៅថាកម្មវិធី Whole Child Model (WCM)។

មុនពេលមានច្បាប់ថ្មីនេះ កុមារមានបញ្ហាសុខភាពដែលមានសិទ្ធិទទួលបាន CCS បានទទួលការថែទាំពីកម្មវិធី CCS របស់ខោនធីផង **និង**គម្រោងសុខភាព Medi-Cal នៅក្នុងបណ្តាខោនធីដែលគ្មានកម្មវិធី WCM ផង។ ឥឡូវនេះ ជាមួយនឹងកម្មវិធី WCM គម្រោង Medi-Cal នឹងសម្របសម្រួលសេវាកម្មទាំងអស់តាមរយៈតែគម្រោងសុខភាព Medi-Cal របស់កុមារប៉ុណ្ណោះ។

ខោនធីទាំង 33 នេះ ឥឡូវនេះនឹងមានកម្មវិធី WCM៖ Butte, Colusa, Del Norte, Glenn, Humboldt, Lake, Lassen, Marin, Mariposa, Mendocino, Merced, Modoc, Monterey, Napa, Nevada, Orange, Placer, Plumas, San Benito, San Luis Obispo, San Mateo, Santa Barbara, Santa Cruz, Shasta, Sierra, Siskiyou, Solano, Sonoma, Sutter, Tehama, Trinity, Yolo និង Yuba។

## 2. តើកម្មវិធី WCM ជាអ្វី?

កម្មវិធី WCM ជួយកុមារក្នុងកម្មវិធី CCS ដែលមានសិទ្ធិទទួលបានគម្រោង Medi-Cal និងគ្រួសាររបស់ពួកគេឱ្យទទួលបានការសម្របសម្រួលការថែទាំ លទ្ធភាពទទួលបានការថែទាំ និងលទ្ធផលសុខភាពបានកាន់តែប្រសើរ។

## 3. តើគម្រោងសុខភាព Medi-Cal ធ្វើការជាមួយកម្មវិធី WCM យ៉ាងដូចម្តេច?

នៅក្នុងបណ្តាខោនធីដែលមានកម្មវិធី WCM គម្រោងសុខភាព Medi-Cal សម្របសម្រួល និងអនុម័តការថែទាំសម្រាប់សមាជិកដែលមានបញ្ហាសុខភាពដែលមានសិទ្ធិទទួល CCS។ វេជ្ជបណ្ឌិត និងអ្នកឯកទេសដែលជាផ្នែកមួយនៃក្រុមការងារគម្រោងសុខភាព Medi-Cal ជាអ្នកផ្តល់សេវាកម្ម CCS។ វេជ្ជបណ្ឌិត និងអ្នកឯកទេសទាំងនេះគឺជាអ្នកផ្តល់សេវាដែលជ្រើសរើសដោយកម្មវិធី CCS ដែលពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើការជាមួយសមាជិក CCS។ ប្រសិនបើសមាជិកត្រូវការការថែទាំ ដែលគ្មាននៅក្នុងបណ្តាញគម្រោងសុខភាព Medi-Cal នោះគម្រោងសុខភាព Medi-Cal នឹងជួយសមាជិក CCS ឱ្យទទួលបានការថែទាំដែលពួកគេត្រូវការ។



MU_0005221_CAM1_0624

4. **តើកូនរបស់ខ្ញុំអាចរក្សាអ្នកផ្តល់សេវា CCS ដដែលបានដែរទេ?**

   កូនរបស់អ្នកប្រហែលជាអាចរក្សាអ្នកផ្តល់សេវា CCS បាន ទោះបីជាអ្នកផ្តល់សេវាស្ថិតនៅក្រៅបណ្តាញគម្រោងសុខភាព Medi-Cal ក៏ដោយ។ សួរអ្នកផ្តល់សេវា CCS របស់កូនអ្នក ថាតើពួកគេធ្វើការជាមួយគម្រោងសុខភាព Medi-Cal របស់កូនអ្នកដែរឬទេ។ ប្រសិនបើអ្នកផ្តល់សេវាដែលជ្រើសរើសដោយ CCS ធ្វើការជាមួយគម្រោង នោះកូនរបស់អ្នកអាចរក្សាអ្នកផ្តល់សេវាដដែលបាន។ បើមិនដូច្នេះទេ កូនរបស់អ្នកអាចនៅរក្សាអ្នកផ្តល់សេវា CCS ដដែលរហូតដល់ 12 ខែ ឬយូរជាងនេះបាន។ ដំណើរការនេះហៅថា "ការបន្តការថែទាំ" (continuity of care)។ សម្រាប់ព័ត៌មានបន្ថែម អ្នកអាចសួរខាងគម្រោងសុខភាព Medi-Cal របស់កូនអ្នកបាន។ កូនរបស់អ្នកអាចរក្សាអ្នកផ្តល់សេវា CCS បាន បើទោះបីជាអ្នកផ្តល់សេវាមិនស្ថិតនៅក្នុងបណ្តាញ (OON) ក៏ដោយ។ អ្នកអាចទូរសព្ទទៅខាងគម្រោងសុខភាព Medi-Cal របស់កូនអ្នកដើម្បីស្នើសុំរក្សាអ្នកផ្តល់សេវា CCS ដដែល ឱ្យតែអ្នកផ្តល់សេវា CCS និងគម្រោងសុខភាព Medi-Cal របស់កូនអ្នកអាចធ្វើការជាមួយគ្នាបាន។

5. **តើកូនរបស់ខ្ញុំអាចរក្សាអ្នកគ្រប់គ្រងករណី CCS ដដែលបានដែរទេ?**

   អ្នកអាចសួររក "ការបន្តការថែទាំ" (continuity of care) ដើម្បីរក្សាអ្នកគ្រប់គ្រងករណី CCS របស់កូនអ្នក ឬគិលានុបដ្ឋាយិកាសុខភាពសាធារណៈបាន។ ប្រសិនបើគម្រោងសុខភាព Medi-Cal និងខោនធីមិនអាចឈានដល់ការព្រមព្រៀងគ្នាទេ នោះកូនរបស់អ្នកនឹងត្រូវបានចាត់តាំងទៅឱ្យអ្នកគ្រប់គ្រងករណីម្នាក់តាមរយៈគម្រោងសុខភាព Medi-Cal របស់ពួកគេ។

6. **តើកូនរបស់ខ្ញុំនឹងរក្សាបានអត្ថប្រយោជន៍ CCS ដដែលនៅក្នុងកម្មវិធី WCM ដែរទេ?**

   បាន។ កូនរបស់អ្នកនឹងមានអត្ថប្រយោជន៍ CCS ដដែលនៅក្នុងកម្មវិធី WCM។ កូនរបស់អ្នកនឹងរក្សាបាននូវការទទួលសេវាកម្ម CCS ដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងមានវេជ្ជបញ្ជាពីអ្នកផ្តល់សេវារបស់កូនរបស់អ្នក។

7. **តើធ្វើដូចម្តេចទើបខ្ញុំដឹងថាកូនរបស់ខ្ញុំនឹងបានចូលក្នុងកម្មវិធី WCM?**

   កូនរបស់អ្នកនឹងបានចូលកម្មវិធី WCM ប្រសិនបើកូនរបស់អ្នកបានចុះឈ្មោះក្នុងគម្រោងសុខភាព Medi-Cal ដែលស្ថិតក្នុងខោនធីមួយក្នុងចំណោមខោនធីទាំង 33 ដែលបានរៀបរាប់ឈ្មោះនៅក្នុងសំណួរ #1 និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្ម CCS។

8. **តើកម្មវិធី WCM នឹងផ្លាស់ប្តូរដំណើរការ ដើម្បីទទួលបានការថែទាំរបស់ CCS ដែរឬទេ?**

   កម្មវិធី WCM សម្របសម្រួលសកម្មភាពថែទាំកូនរបស់អ្នកទាំងអស់ និងចែករំលែកព័ត៌មានជាមួយអ្នកផ្តល់សេវារបស់កូនរបស់អ្នក។ បែបនេះធានាថាកូនរបស់អ្នកទទួលបានការថែទាំទាំងអស់របស់ពួកគេ រួមទាំងគ្រឿងផ្គត់ផ្គង់ និងសេវាកម្ម CCS ពីគម្រោងសុខភាព Medi-Cal របស់កូនអ្នក។ កម្មវិធី WCM នឹងឱ្យកូនរបស់អ្នកទទួលបានការថែទាំលក្ខណៈឯកទេស ដោយផ្អែកលើបញ្ហាសុខភាពដែលមានសិទ្ធិទទួល CCS របស់ពួកគេ។ WCM នឹងព្យាយាមរក្សាអ្នកផ្តល់សេវា CCS ដដែលឱ្យកូនរបស់អ្នក។

9. **តើខ្ញុំអាចស្វែងយល់បន្ថែម ឬទទួលជំនួយនៅកន្លែងណា?**

   - ប្រសិនបើអ្នកមានសំណួរអំពីសេវាកម្ម CCS និងកម្មវិធី WCM របស់កូនអ្នក សូមហៅទូរសព្ទទៅកាន់គម្រោងសុខភាព Medi-Cal របស់កូនអ្នក។ លេខទូរសព្ទគឺនៅលើខ្នងប័ណ្ណគម្រោងសុខភាព Medi-Cal របស់កូនអ្នក។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។

   - អ្នកក៏អាចហៅទូរសព្ទទៅការិយាល័យ CCS ប្រចាំខោនធីរបស់កូនអ្នកផងដែរ ដើម្បីសួរសំណួរ។ ដើម្បីរកលេខទូរសព្ទរបស់ខោនធី សូមចូលទៅកាន់គេហទំព័រ **www.dhcs.ca.gov/services/ccs/Pages/CountyOffices.aspx**។



MU_0005221_CAM2_0624

- ដើម្បីស្វែងយល់បន្ថែមអំពីជម្រើសនានាសម្រាប់គម្រោងសុខភាព និងអ្នកផ្តល់សេវា (វេជ្ជបណ្ឌិត ឬគ្លីនិក) សូមហៅទូរសព្ទទៅកាន់ Medi-Cal Health Care Options (HCO) ថ្ងៃចន្ទ – ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច តាមរយៈលេខ **1-800-430-5005** (TTY: 1-800-430-7077)។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។ ឬចូលទៅកាន់គេហទំព័រ **www.healthcareoptions.dhcs.ca.gov**។

- ប្រសិនបើអ្នកមានសំណួរអំពីគម្រោង Medi-Cal សូមហៅទូរសព្ទទៅកាន់ខ្សែទូរសព្ទជំនួយ Medi-Cal របស់ Department of Health Care Services (DHCS) ថ្ងៃចន្ទ – ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច តាមរយៈលេខ **1-800-541-5555**។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។

- ប្រសិនបើអ្នកមានបណ្តឹង ឬបញ្ហាជាមួយនឹងគម្រោង Medi-Cal សូមហៅទូរសព្ទទៅកាន់ការិយាល័យ Medi-Cal Ombudsman ថ្ងៃចន្ទ – ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច តាមរយៈលេខ **1-888-452-8609** (TTY: 711 សម្រាប់ California State Relay)។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។ ឬផ្ញើអ៊ីមែលតាម **MMCDOmbudsmanOffice@dhcs.ca.gov**។ ពួកគេជួយប្រជាពលរដ្ឋដែលមានកម្មវិធី Medi-Cal ឱ្យប្រើប្រាស់អត្ថប្រយោជន៍របស់គេ និងយល់ដឹងពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ។